**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៣៣៥ សហវ

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការដឹកនាំគំរោងស្រោចស្រពស្ទឹងជីនិត និងហេដ្ឋារចនាសម្ព័ន្ធជនបទ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/១១៩៨/៧២ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ:០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ :០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ : នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងឥណទានសម្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី លេខ ១៧៩៣ - CAM(SF) ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០០ ។

# សំរេច

**ប្រការ១:** បង្កើតគណៈកម្មការដឹកនាំគំរោងមួយ ( Project Steering Committee, PSC ) ក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី លេខ ១៧៥៣-CAM(SF)(គំរោងការស្តារប្រព័ន្ធស្រោចស្រពស្ទឹងជីនិត និងហេដ្ឋារចនាសម្ព័ន្ធជនបទ)។

**ប្រការ២:** សមាសភាពនៃគណៈកម្មការនេះរួមមាន:

| | | |
|---|---|---|
| - ឯកឧត្តម ញាណ ឡេង | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាប្រធាន |
| - ឯកឧត្តម វេង សាខុន | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| - ឯកឧត្តម ទី ចំនួផល | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - ឯកឧត្តម អ៊ិត ណូឌី | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - លោក ចាន់ សុធី | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - លោក ឡោ ជាវុធ | ប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្រ្ត នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - លោក រិត ឧត្តី | ប្រធាននាយកដ្ឋានគ្រប់គ្រងជំនួយពហុភាគី នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / គណៈកម្មការនីតិសម្បទា និងអភិវឌ្ឍន៍ (ក.អ.ក/ គ.ជ.នា) | សមាជិក |
| - លោក ខូន គង់ | អនុប្រធាននាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន | សមាជិក |
| - លោក ភី លីដា | អនុប្រធាននាយកដ្ឋានគ្រឿងចក្រធំៗ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - លោក ហ៊ុ គុណាវុឌ្ឍន៍ | ប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ៧:** គណៈកម្មការដឹកនាំគំរោងត្រូវជួបប្រជុំគ្នាយ៉ាងហោចណាស់បានចំនួនពីរដង ក្នុង ១ឆ្នាំ ដើម្បី :

-សំរបសំរួលលើរាល់សកម្មភាពនានានៃគំរោងស្រោចស្រពស្ទឹងជីនិត និងហេដ្ឋារចនាសម្ព័ន្ធជនបទ ។

-តាមដាន និងជំរុញការអនុវត្តន៏ផែនការយុទ្ធសាស្រ្តសំរាប់គំរោងស្រោចស្រពស្ទឹងជីនិត និងហេដ្ឋារចនាសម្ព័ន្ធជនបទ ។

-ផ្តល់គោលនយោបាយណែនាំ និងសេចក្តីសំរេចផ្សេងៗដែលពាក់ព័ន្ធនឹងការអនុវត្តគំរោងនេះ ។

-ដោះស្រាយរឺផ្តល់អនុសាសន៍ដើម្បីដោះស្រាយរាល់បញ្ហាដែលកើតមាននៅក្នុងអំឡុងពេលនៃការអនុវត្តគំរោង ។

**ប្រការ៨:** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់អង្គភាពគ្រប់គ្រងស្រោចស្រពស្ទឹងជីនិត និងហេដ្ឋារចនាសម្ព័ន្ធជនបទ ជាលេខាធិការដ្ឋានរបស់ខ្លួន សំរាប់ដំណើការការងារ និងធ្វើរបាយការណ៏ជាទៀងទាត់រួមទាំងរបាយការណ៏ក្រោយពេលប្រជុំជូនគណៈកម្មការដឹកនាំគំរោងស្រោចស្រពស្ទឹងជីនិត និងហេដ្ឋារចនាសម្ព័ន្ធជនបទ ។

**ប្រការ៩:** អគ្គលេខាធិការ នាយកខុទ្ទការល័យ នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ KWE

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០០២

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- គ. ជ. ទា
- ដូចប្រការ៧
- ឯកសារកាលប្បវត្តិ